# ហោរាដ៏ស្ទាក់ស្ទើរបំផុត
# របស់ព្រះ៖
# យ៉ូណាស

JONAH:
GOD'S MOST RELUCTANT
PROPHET

TRUTH FOR LIFE

Jonah - Gods Most Reluctant Prophet - 1.4.indd 1 9/6/26 9:03 in the morning

plovpit.com

ហោរាដ៏ស្ទាក់ស្ទើរបំផុតរបស់ព្រះ៖ យ៉ូណាស

Jonah: God's Most Reluctant Prophet

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម @ ២០២៦

និពន្ធដោយ៖ លោកគ្រូ Alistair Begg

បកប្រែដោយ៖ ACTION Cambodia Organization

All rights reserved by original authors © 2024

Used by permission

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

បកប្រែដោយ៖ លោក ឯក សត្យា

ជំនួយការបកប្រែដោយ៖ លោក ឈាង បូរ៉ា

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក វ៉ែល ណាថាន, លោក ទេព រ៉ូ, អ្នកស្រី ឡូញ ស្រីរដ្ឋ
លោក ខែម បូឡុង, លោក ហុង សម្កុស, លោក ឡង់ គីមឡុង, លោក ឯក សត្យា
និង លោក ស៊ូ ទិត្យ

ការប្រើប្រាស់បទព្រះគម្ពីរបរិសុទ្ធ និងដ៏វិសុទ្ធ និងព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤មានការអនុញ្ញាតពីសមាគមព្រះគម្ពីរកម្ពុជា និងរក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត។

មានការអនុញ្ញាតការប្រើប្រាស់បទព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ-សញ្ញាថ្មី រក្សាសិទ្ធិ © ២០១២

ព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។ យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក ខែម បូឡុង

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ www.plovpitshop.com

បោះពុម្ពលើកទី១ ចំនួន៣០០០ក្បាល គ.ស. ២០២៦ នៅព្រះរាជាណាចក្រកម្ពុជា

Jonah - Gods Most Reluctant Prophet - 1.4.indd 2 9/6/26 9:03 in the morning

# មាតិកា


ទឹកចាំអំពីសេចក្តីមេត្តារបស់ព្រះ ............................................ ៥

ការមិនស្តាប់បង្គាប់ និងការស្ទាក់ស្ទើរ ..................................... ៩

ព្រះអម្ចាស់លើគ្រប់ទាំងអស់ ............................................... ១៣

ដីគោកកំពុងរង់ចាំ ......................................................... ១៧

ប្រកាសអំពីសេចក្តីមេត្តារបស់ព្រះ ........................................ ២១

ការប្រាប់ឲ្យប្រែចិត្ត ......................................................... ២៥

ព្រះនៃយើងមិនប្រែប្រួល .................................................... ២៩

ស្របតាមផែនការរបស់ព្រះ ............................................... ៣៣

អ្នកបម្រើដែលមិនស័ក្តិសមរបស់ព្រះ ................................... ៣៧

ការរៀបចំដ៏អាច់កំបាំងរបស់ព្រះអង្គ ..................................... ៤១

រឿងដែលគួរខ្វល់ ............................................................. ៤៥

# នឹកចាំអំពីសេចក្ដីមេត្តារបស់ព្រះ

*«រីឯព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់យ៉ូណាសជាកូនអ័មីថាយថា ចូរក្រោកឡើងទៅឯនីនីវេ ជាទីក្រុងធំ ហើយស្រែកប្រកាសទាស់នឹងក្រុងនោះ ពីព្រោះអំពើអាក្រក់របស់គេបានសាយឡើងនៅចំពោះមុខអញហើយ ប៉ុន្តែយ៉ូណាស លោកក្រោកឡើង រត់ទៅឯក្រុងតើស៊ីសវិញ ដើម្បីឲ្យរួចពីព្រះភក្ត្រនៃព្រះយេហូវ៉ា» (យ៉ូណាស ១:១-៣)។*

ព្រះអម្ចាស់សប្បាយព្រះទ័យក្នុងការសង្គ្រោះរាស្ត្រព្រះអង្គ។

កាលព្រះអង្គបង្គាប់លោក យ៉ូណាស ជាអ្នកបម្រើឲ្យទៅទីក្រុងនីនីវេ ហើយប្រកាសព្រះបន្ទូលឲ្យទីក្រុងនេះប្រែចិត្តចេញពីការអាក្រក់ ហោរាដែលកំពុងមានចិត្តស្ទាក់ស្ទើរនេះបានទទួលស្គាល់ថា ប្រជាជននៅទីនោះអាចប្រែចិត្តចេញពីការអាក្រក់ ហើយព្រះអម្ចាស់នឹងឆ្លើយតប ដោយសេចក្តីមេត្តា (យ៉ូណាស ៤:២)។ គាត់ដឹងថា ព្រះអម្ចាស់ជា “យេហូវ៉ា គឺយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តី



Jonah - Gods Most Reluctant Prophet - 1.4.indd 5 9/6/26 9:03 in the morning

សប្បុរស និងសេចក្ដីទៀងត្រង់ជាបរិបូរ ទ្រង់មានសេចក្ដីមេត្តាករុណាដល់មនុស្សទាំងពាន់ ក៏អត់ទោសចំពោះសេចក្ដីទុច្ចរិត សេចក្ដីរំលង និងអំពើបាប ប៉ុន្តែទ្រង់មិនរាប់មនុស្សមានទោសទុកជាឥតទោសឡើយ»(និក្ខមនំ ៣៤:៦-៧)។ គាត់បានដឹងសេចក្ដីពិតដែលថា ថ្ងៃមួយព្រះទ្រង់នឹងមានបន្ទូលតាមហោរាយេរេមាថា «នៅវេលាណាដែលអញនិយាយពីដំណើរសាសន៍ណា ឬនគរណាថា នឹងដករំលើងគេ ព្រមទាំងរំលំ ហើយបំផ្លាញផង។ បើសិនជានគរដែលអញបាននិយាយនោះ នឹងបែរចេញពីអំពើអាក្រក់របស់ខ្លួន នោះអញនឹងប្រែគំនិតចេញពីការអាក្រក់ ដែលអញបានគិតធ្វើដល់គេក្នុងវេលានោះឯង»(យេរេមា ១៨:៧-៨)។

ហោរា យ៉ូណាស ដឹងថា ព្រះអម្ចាស់មានព្រះទ័យមេត្តា តែគាត់បានបដិសេធន៍មិនព្រមស្ដាប់បង្គាប់តាមព្រះរាជបញ្ជារបស់ព្រះអង្គ។ តើហេតុអ្វី? គាត់ប្រហែលជាគ្រាន់តែមិនចូលចិត្តប្រជាជននៅទីក្រុងនីនីវេ ហើយនៅសម័យនោះ គេឮល្បីថា ប្រជាជននៅទីក្រុងនីនីវេ ជាមនុស្សថ្វាយបង្គំព្រះដទៃ ពួកគេកាចសាហាវ និងមានហិង្សា ហើយជាខ្មាំងសត្រូវដ៏គួរឲ្យភ័យខ្លាចរបស់ប្រជាជនអ៊ីស្រាអែល។ ហោរា យ៉ូណាស មិនចង់ឲ្យព្រះអម្ចាស់ទុកជីវិតឲ្យពួកគេទេ។ ហេតុនេះហើយ ក្រោយមកនៅពេលដែលប្រជាជននៅទីក្រុងនីនីវេបានងាកបែរចេញពីការអាក្រក់ «ការនោះជាទីទំនាស់ចិត្តដល់យ៉ូណាសយ៉ាងក្រៃលែង ហើយលោកក៏ខឹង»(យ៉ូណាស ៤:១)។ ហោរា យ៉ូណាស



Jonah - Gods Most Reluctant Prophet - 1.4.indd 6 9/6/26 9:03 in the morning

យល់ឃើញថា ពួកគេសមនឹងទទួលការជំនុំជម្រះពីព្រះ។ គាត់គិតត្រូវ! ប៉ុន្តែ អរព្រះគុណព្រះអង្គ ដែលបានប្រព្រឹត្តចំពោះប្រជាជាតិ ទីក្រុង និងបុគ្គលម្នាក់ៗតាមផ្លូវរបស់ព្រះអង្គ តែមិនតាមផ្លូវយើង។ ព្រះអង្គមានសព្វព្រះទ័យនឹងបង្ហាញសេចក្តីមេត្តា គឺមិនចង់ឲ្យពួកគេវិនាសឡើយ។

សេចក្តីអាណិតដែលព្រះអង្គមានចំពោះប្រជាជននៅទីក្រុងនីនីវេ គឺបានរំឮកយើងថា ព្រះអង្គមិនសព្វព្រះទ័យឲ្យនរណាម្នាក់វិនាសទេ ហើយព្រះអង្គសព្វព្រះទ័យនឹងជួយសង្គ្រោះមនុស្ស ជាពិសេសអ្នកដែលហាក់ដូចជាសមនឹងវិនាសបំផុត (២ពេត្រុស ៣:៩)។ លោក យ៉ូណាស ចង់ប្រកាសព្រះបន្ទូល តែនៅកន្លែងណាដែលគាត់ចង់ប្រកាស និងទៅកាន់មនុស្សណាដែលគាត់ចង់ប្រកាសប្រាប់ប៉ុណ្ណោះ។ ប៉ុន្តែ ដំណឹងល្អគឺសម្រាប់មនុស្សគ្រប់ៗគ្នា គ្រប់ទីកន្លែង។ សព្វថ្ងៃនេះ ដំណឹងល្អរបស់ព្រះយេស៊ូវមិនមែនសម្រាប់តែមនុស្ស «មានអាកប្បកិរិយាល្អ» ប៉ុណ្ណោះទេ តែក៏សម្រាប់មនុស្សមានរូបសម្បត្តិ ការប្រព្រឹត្ត និងការគិតដូចយើងផងដែរ។ ជាការពិតណាស់ ព្រះយេស៊ូវបានបង្គាប់អ្នកដើរតាមព្រះអង្គថា «ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍»(ម៉ាថាយ ២៨:១៩)។

ព្រះអង្គមានសេចក្តីមេត្តាលើសលប់! ព្រះអង្គមានព្រះទ័យអាណិតនៅក្នុងការតាមជួយសង្គ្រោះមនុស្សដែលមានអំនួត រឹងទទឹង និងល្មើសក្រឹត្យវិន័យរបស់ព្រះអង្គ គឺមនុស្សដូចអ្នក និងខ្ញុំ។ ព្រះអង្គ

ត្រាស់ហៅយើង ឲ្យមានចិត្តឧស្សាហ៍នៅក្នុងការនាំសេចក្ដីសង្គ្រោះទៅដល់មនុស្សដែលកំពុងវិនាស និងមើលថែមនុស្សដែលកំពុងស្លាប់ ហើយប្រាប់ពួកគេអំពីព្រះយេស៊ូវ ជាព្រះមានចេស្ដា ដែលអាចជួយសង្គ្រោះ។[១] ព្រះត្រៃឯកសព្វព្រះទ័យនឹងជួយសង្គ្រោះមនុស្សមានបាប គឺសព្វព្រះទ័យខ្លាំងល្មមនឹងយាងចុះមក ហើយសុគតជំនួសពួកគេ។ តើអ្នកមានចិត្តដូចព្រះអង្គទេ? បើអ្នកមានមែន នោះអ្នកក៏នឹងមានចិត្តចង់ឲ្យមនុស្សនៅជុំវិញអ្នកបានសង្គ្រោះផងដែរ។ ទោះពួកគេជានរណា ហើយបានធ្វើអ្វីក៏ដោយ គឺល្មមនឹងចេញទៅ ហើយចែកចាយអំពីព្រះគ្រីស្ទដល់ពួកគេ។

*ព្រះគម្ពីរសញ្ជឹងគិត៖ ១កូរិនថូស ៩:១៩-២៣*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៧៤-៧៦ និង*
*កិច្ចការ ២៧:១-២៦*

១ លោកស្រី Fanny Crosby, "Rescue the Perishing" (ឆ្នាំ១៨៦៩)។



Jonah - Gods Most Reluctant Prophet - 1.4.indd 8 9/6/26 9:03 in the morning

# ការមិនស្តាប់បង្គាប់ និងការស្ទាក់ស្ទើរ

*«យ៉ូណាស លោកក្រោកឡើង រត់ទៅឯក្រុងតើស៊ីសវិញ ដើម្បីឲ្យរួចពីព្រះភក្ត្រនៃព្រះយេហូវ៉ា គឺលោកចុះទៅដល់ក្រុងយ៉ុបប៉េបានប្រទះនឹងនាវា១ ដែលរៀបចេញទៅឯក្រុងតើស៊ីស នោះលោកចេញប្រាក់ជាដំឡៃជិះ រួចក៏ចុះនាវានោះ ដើម្បីទៅឯតើស៊ីសជាមួយនឹងគេឲ្យរួចពីព្រះភក្ត្រព្រះយេហូវ៉ា» (យ៉ូណាស ១:៣)។*

ជានិច្ចកាល ដំណើរនៃការមិនស្តាប់បង្គាប់ គឺជាដំណើរដាំក្បាលចុះក្រោម ទាល់តែព្រះទ្រង់ចូលធ្វើអន្តរាគមន៍។ ក្នុងដំណើរដែលហោរា យ៉ូណាស ប្រញាប់រត់គេចពីព្រះរាជបញ្ជារបស់ព្រះអម្ចាស់ឲ្យទៅផ្សាយព្រះបន្ទូលនៃកាប្រែចិត្ត ទៅដល់ទីក្រុងនីនីវេ គាត់បានចុះទៅដល់ក្រុងយ៉ុបប៉េ រួចឡើងជិះសំពៅទៅកាន់ទឹកដីមួយ តែនៅតាមផ្លូវ គាត់ត្រូវត្រីធំលេបចូលទៅក្នុងពោះ (យ៉ូណាស ២:៦)។ នៅពេលដែលលោក យ៉ូណាស កំពុងគេងលក់នៅក្នុងសំពៅនោះ ក្នុងដំណើររត់គេចពីព្រះអម្ចាស់ "ទ្រង់ធ្វើឲ្យមានខ្យល់យ៉ាងខ្លាំង



Jonah - Gods Most Reluctant Prophet - 1.4.indd 9 9/6/26 9:03 in the morning

បក់មកលើសមុទ្រ ដូច្នេះកើតមានព្យុះយ៉ាងធំនៅសមុទ្រ ដល់ម្លេះបានជានាវារកកល់តែនឹងបែកបាក់អស់ទៅ»(១:៤)។ ប៉ុន្តែ ហោរា យ៉ូណាស នៅតែបន្តគេងលក់នៅក្នុងខ្យល់ព្យុះដ៏កាចសាហាវ និងភាពជ្រួលច្របល់របស់ពួកនាវិក ដែលកំពុងស្រែកស្លន់ស្លោ ទួញយំ និងបួសសួងទៅព្រះរបស់គេរៀងខ្លួន ហើយក៏បានបោះរបស់របរចូលទៅក្នុងទឹក។

តើលោក យ៉ូណាស អាចខ្សោះអស់កម្លាំងខ្លាំងយ៉ាងនេះ ដោយរបៀបណា? ជាការពិតណាស់ គាត់មានការហត់នឿយទាំងខាងផ្លូវកាយ និងវិញ្ញាណ ដោយសារគាត់បានសម្រេចចិត្តរត់គេចពីព្រះអង្គ។ ការមិនស្តាប់បង្គាប់អាចធ្វើឲ្យយើងរំភើបរីករាយបានតែមួយរយៈពេលខ្លី តែវាក៏ធ្វើឲ្យយើងខ្សោះអស់កម្លាំងនៅទីបញ្ចប់។ ការយកជើងទៅធាក់ជន្លួញ គឺមិនស្រួលទេ (កិច្ចការ ២៦:១៤)។ មានរឿងតិចណាស់ដែលវេទនាជាងការគេងលក់ដ៏ហត់នឿយ បន្ទាប់ពីយើងមិនអើពើចំពោះព្រះបន្ទូលព្រះ ហើយការបះបោររបស់យើងក្លាយជាបន្ទុកដ៏ធ្ងន់។ នៅពេលនោះ យើងគ្រាន់តែចង់ដកខ្លួនចេញពីមនុស្សរាល់គ្នា ហើយលាក់ខ្លួននៅក្នុងដំណេកដាច់ចេញពីគេ។

លោក យ៉ូណាស ចង់ឲ្យព្រះអម្ចាស់ឈប់រំខានគាត់ទៀត។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់មានសេចក្តីមេត្តាយ៉ាងខ្លាំង បានជាមិនអាចធ្វើតាមចិត្តគាត់បាន។ ព្រះអង្គក៏បានបញ្ជូនខ្យល់ព្យុះមួយមក ហើយខ្យល់ព្យុះក៏បានបណ្តាលឲ្យនាយនាវាទៅរក



Jonah - Gods Most Reluctant Prophet - 1.4.indd 10 9/6/26 9:03 in the morning

លោក យ៉ូណាស ហើយដាស់ឲ្យគាត់ក្រោក។ នាយនាវាក៏បានប្រើពាក្យសម្ដី ដូចកាលព្រះបានមានបន្ទូលត្រាស់ហៅគាត់ឲ្យប្រកាសព្រះបន្ទូលថា «ចូរក្រោកឡើងអំពាវនាវដល់ព្រះនៃអ្នកទៅ»(មើល យ៉ូណាស ១:៦ ធៀបនឹង ១:២)។

បន្ទាប់មក លោក យ៉ូណាស ក៏បានបង្ហាញនូវការស្ទាក់ស្ទើរក្នុងការធ្វើអ្វីដែលគេបានប្រាប់ឲ្យគាត់ធ្វើ តែព្រះអម្ចាស់ក៏មិនសព្វព្រះទ័យឲ្យអ្នកបម្រើរបស់ព្រះអង្គបន្តរស់នៅក្នុងការពិបាកចិត្ត និងទុក្ខវេទនាក្នុងបាបរបស់ខ្លួនទៀតទេ។ រយៈពេលបីថ្ងៃ ដែលលោក យ៉ូណាស នៅក្នុងពោះត្រីធំក៏បានធ្វើបន្ទាល់ជាបន្ថែមទៀត អំពីសេចក្ដីពិតនេះ។ ទោះការបះបោររបស់លោក យ៉ូណាស សមនឹងទទួលការជំនុំជម្រះក៏ដោយ ក៏មិនយូរប៉ុន្មាន ព្រះអង្គក៏បានជួយសង្គ្រោះគាត់ឲ្យរួចផុតពីសេចក្ដីហិនវិនាសក្នុងទឹកសមុទ្រ ហើយក៏បានស្អាងគាត់ឡើងវិញ ដើម្បីឲ្យគាត់អាចចែកចាយអំពីការជំនុំជម្រះ និងសេចក្ដីមេត្តារបស់ព្រះអង្គទៅកាន់អ្នកក្រុងនីនីវេ។

ព្រះទ្រង់យាងមករកយើងម្ដងហើយម្ដងទៀត ពេលដែលយើងមិនស្ដាប់បង្គាប់ ដោយព្រះអង្គមិនព្រមឲ្យយើងបន្តរស់នៅក្នុងបាបរបស់យើងទៀតទេ។ ទោះយើងយកម្រាមដៃញ៉ុកត្រចៀក ហើយធ្វើពុតជាមិនបានឮព្រះអង្គ ហើយថែមទាំងបដិសេធមិនស្ដាប់បង្គាប់ដោយត្រង់ៗក៏ដោយ ក៏ព្រះអង្គនៅតែតាមហៅយើង ជាកូនព្រះអង្គដែលកំពុងវង្វេង។ ព្រះអង្គស្រឡាញ់យើងខ្លាំងណាស់បានជាព្រះអង្គ

មិនចង់ទុកឲ្យយើងដើរតាមផ្លូវរបស់យើងទេ។ ពេលយើងរស់នៅក្នុង
អំពើបាប យើងមិនអាចឈ្នះសេចក្តីមេត្តារបស់ព្រះអង្គ ជាព្រះដែល
មិនចាកចោលយើង ឬបោះបង់ចោលយើងឡើយ។

*ព្រះគម្ពីរសញ្ជឹងគិត៖ យ៉ូណាស ១*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៧៧-៧៨ និង*
*កិច្ចការ ២៧:២៧-៤៤*



Jonah - Gods Most Reluctant Prophet - 1.4.indd 12 9/6/26 9:03 in the morning

# ព្រះអម្ចាស់លើគ្រប់ទាំងអស់

*«យ៉ូណាស លោកក្រោកឡើង រត់ទៅឯក្រុងតើស៊ីសវិញ ដើម្បីឲ្យរួចពីព្រះភក្ត្រនៃព្រះយេហូវ៉ា គឺលោកចុះទៅដល់ក្រុងយ៉ុបប៉េបានប្រទះនឹងនាវា១ ដែលរៀបចេញទៅឯក្រុងតើស៊ីស នោះលោកចេញប្រាក់ជាដំឡៃជិះ រួចក៏ចុះនាវានោះ ដើម្បីទៅឯតើស៊ីសជាមួយនឹងគេ ឲ្យរួចពីព្រះភក្ត្រព្រះយេហូវ៉ា។ ប៉ុន្តែ ព្រះយេហូវ៉ា ទ្រង់ធ្វើឲ្យមានខ្យល់យ៉ាងខ្លាំង បក់មកលើសមុទ្រ ដូច្នេះកើតមានព្យុះយ៉ាងធំនៅសមុទ្រ ដល់ម្ល៉េះបានជានាវារកកល់តែនឹងបែកបាក់អស់ទៅ» (យ៉ូណាស ១:៣-៤)។*

យើងមិនអាចគ្រប់គ្រងធម្មជាតិ ជាស្នាព្រះហស្តរបស់ព្រះអង្គបានទេ។ ប៉ុន្តែ ព្រះអង្គអាចគ្រប់គ្រង ហេតុនេះហើយព្រះអង្គសក្តិសមនឹងទទួលការសរសើរ និងការស្រឡាញ់គ្រប់យ៉ាងពីយើង។

ជាការពិតណាស់ ការគ្រប់គ្រងរបស់ព្រះអង្គមកលើទឹកសមុទ្រ និងស្នាព្រះហស្តទាំងអស់ គឺជាហេតុផលដែលកណ្ឌគម្ពីរទំនុកតម្កើងតែងតែសរសើរតម្កើងព្រះអង្គជានិច្ច។ ពេលយើងអានបទគម្ពីរទំនុកតម្កើង យើងរកឃើញម្តងហើយម្តងទៀតថា រាស្ត្ររបស់ព្រះអរសប្បាយនឹងការសរសើរតម្កើងព្រះចេស្តានៃការគ្រប់គ្រងរបស់ព្រះអង្គ មកលើ



Jonah - Gods Most Reluctant Prophet - 1.4.indd 13 9/6/26 9:03 in the morning

សណ្ដាប់ធ្នាប់ដែលព្រះអង្គបានបង្កើត គឺគ្រប់គ្រងមកលើសមុទ្រ និងថែមទាំងមកលើទឹកជោរ និងទឹកនាចផងដែរ។

ឧទាហរណ៍ យើងឃើញថា បទគម្ពីរទំនុកតម្កើងជំពូក៣៣បានចែងថា «ទ្រង់បង្គរទឹកសមុទ្រឡើង ដូចជាគំនរ ទ្រង់យកទីជំរៅដាក់ទុកក្នុងឃ្លាំង»(ខ.៧)។ នេះជាការពិពណ៌នាគួរឲ្យស្ញប់ស្ញែង និងជាផ្នែកមួយនៃភាពល្អប្រសើរ និងសិរីល្អរបស់ព្រះអង្គ។ យើងអាចធ្វើចលនា ដោយចាក់ទឹកតែក្រូចឆ្មាចូលទៅក្នុងកែវធំ តែព្រះអង្គអាចប្រមូលផ្ដុំទឹកសមុទ្រទាំងអស់ ចាក់ចូលទៅក្នុងជើង។ ដូចនេះ ការថ្វាយបង្គំព្រះអាទិកររបស់យើង ដោយការកោតខ្លាច និងស្ញប់ស្ញែង គឺជាទង្វើដែលត្រឹមត្រូវណាស់។

ដូចគ្នានេះដែរ ការពិពណ៌នាអំពីអំណាចដែលព្រះទ្រង់មានមកលើស្នាព្រះហស្តព្រះអង្គ បានលើកទឹកចិត្តយើងឲ្យទុកចិត្តលើការថែរក្សារបស់ព្រះអង្គ។ ក្នុងរឿងហោរាយ៉ូណាស យើងឃើញថា ក្រោយមកទៀត ព្រះអម្ចាស់ក៏បានធ្វើឲ្យមាន «ដើមវល្លិ» ហើយធ្វើឲ្យមាន «ដង្កូវស៊ីស្លឹករបស់វល្លិនោះ» ហើយក៏បានធ្វើឲ្យមានខ្យល់ក្ដៅមកពីទិសខាងលិច ដើម្បីសម្រេចផែនការ ដែលព្រះអង្គមានសម្រាប់លោកយ៉ូណាស និងអ្នកក្រុងនីនីវេ (យ៉ូណាស ៤:៦-៨)។ រឿងនេះក៏បានបង្ហាញអំពីភាពខុសគ្នារវាងសេចក្ដីពិតនេះ និងផ្នត់គំនិតរបស់អ្នកមិនជឿក្នុងសម័យរបស់ហោរា យ៉ូណាស និងក្នុងសម័យរបស់យើង។ ពួកនាវិកនៅលើសំពៅដែលលោក យ៉ូណាស



Jonah - Gods Most Reluctant Prophet - 1.4.indd 14 9/6/26 9:03 in the morning

បានជិះ បានចាត់ទុកសមុទ្រ ជាអំណាចដែលមិនអាចគ្រប់គ្រងបាន ដែលឃុំគ្រងជីវិតរបស់ពួកគេ។ សព្វថ្ងៃនេះ មនុស្សជាតិក៏ប្រឈមមុខដាក់ផ្នត់គំនិតដែលជឿថា «មាតាធម្មជាតិ» គឺជាអំណាចគ្មានក្តីមេត្តា ដែលមិនអាចផ្សាំងបាន។ ប៉ុន្តែ សេចក្តីពិតបានបង្ហាញថា អ្វីៗទាំងអស់រាប់បញ្ចូលទាំងសណ្តាប់ធ្នាប់ដែលព្រះអង្គបានបង្កើត គឺជាអ្នកបម្រើរបស់ព្រះអង្គ (ទំនុកតម្កើង ១១៩:៩១)។ យើងមិនមែនកំពុងតែរស់នៅរសាត់អណ្តែតនៅលើមហាសមុទ្រនៃយថាកម្ម ឬស្ថិតនៅក្រោមអំណាចងងឹតងងល់ ដែលមិនមែនជាអង្គបុគ្គលនោះទេ។ទេ ព្រះទ្រង់ «រាប់ចំនួននៃអស់ទាំងផ្កាយ ក៏ហៅបានតាមឈ្មោះទាំងអស់»(ទំនុកតម្កើង ១៤៧:៤)។

មានតែព្រះអម្ចាស់ ជាព្រះអាទិករដែលមានអំណាចគ្រប់គ្រងទេ ដែលអាចប្រមូលផ្តុំសមុទ្រទាំងអស់ដាក់គរពីលើគ្នា ហើយបង្គាប់ស្នាព្រះហស្តទាំងអស់ឲ្យធ្វើតាមព្រះទ័យព្រះអង្គ។ មិនតែប៉ុណ្ណោះ ព្រះអង្គក៏បានសម្រេចព្រះទ័យប្រើព្រះរាជបញ្ជារបស់ព្រះអង្គ ជាប្រយោជន៍ដល់រាស្ត្រព្រះអង្គ។ ខ្យល់ព្យុះដែលព្រះទ្រង់បានបណ្តាលឲ្យកើតឡើងនៅលើសមុទ្រ ខណៈពេលដែលសំពៅនោះកំពុងធ្វើដំណើរទៅស្រុកតើស៊ីស មិនមែនជាបណ្តាសារមកលើគាត់ទេ តែជាការត្រាស់ហៅគាត់ឲ្យវិលត្រឡប់មករកការស្តាប់បង្គាប់ដ៏ស្មោះត្រង់ចំពោះព្រះរបស់គាត់។ ការអ្វីដែលព្រះទ្រង់ទម្លាក់មកលើលោក យ៉ូណាស នោះព្រះអង្គក៏បានសង្គ្រោះគាត់ឲ្យរួចពីវាផងដែរ។



Jonah - Gods Most Reluctant Prophet - 1.4.indd 15 9/6/26 9:03 in the morning

អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ព្រះអម្ចាស់បានប្រើអំណាចដ៏លើសលប់របស់ខ្យល់ព្យុះ គ្រាន់តែដើម្បីនាំក្មេងមិនស្ដាប់បង្គាប់ម្នាក់ឲ្យត្រឡប់មករកព្រះអង្គវិញ។

ជាការពិតណាស់ គ្រប់យ៉ាងត្រូវបានរៀបចំមក ដើម្បីថ្វាយសិរីល្អដល់ព្រះ និងដើម្បីប្រយោជន៍រាស្ត្រព្រះអង្គ ដោយរាប់បញ្ចូលទាំងអ្នកផងដែរ។ ព្រះអង្គជាព្រះដែលយើងសរសើរតម្កើង ទុកចិត្ត ហើយថ្វាយជីវិតយើងដាច់ដល់ព្រះអង្គ។ នៅថ្ងៃនេះ ចូរយើងប្រកាសសេចក្ដីពិតនេះថា «ព្រះយេហូវ៉ាទ្រង់ធំប្រសើរ គឺគួរសរសើរយ៉ាងក្រៃលែង ឯសណ្ឋានធំប្រសើររបស់ទ្រង់ នោះនឹងរកយល់មិនបាន»(ទំនុកតម្កើង ១៤៥:៣)។

*ព្រះគម្ពីរសញ្ជឹងគិត៖ ទំនុកតម្កើង ១៤៥*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៧៩-៨០ និង*
*កិច្ចការ ២៨*



Jonah - Gods Most Reluctant Prophet - 1.4.indd 16 9/6/26 9:03 in the morning

# ដីគោកកំពុងរង់ចាំ

*«ក្នុងរវាងនោះ យ៉ូណាសក៏អធិស្ឋានដល់ព្រះយេហូវ៉ា ជាព្រះនៃខ្លួនពីក្នុងពោះត្រី។ លោកទូលថា ទូលបង្គំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយព្រោះទុក្ខលំបាករបស់ទូលបង្គំ ទ្រង់ក៏បានឆ្លើយមកទូលបង្គំហើយ» (យ៉ូណាស ២:២-៣)។*

ពាក្យសម្ដីរបស់លោក យ៉ូណាស ក្នុងបទគម្ពីរខាងលើនេះ ក៏ជាពាក្យសម្ដីសម្រាប់អ្នកជឿ ដែលកំពុងតយុទ្ធ និងកំពុងជួបភាពអន់ថយខាងជំនឿ ក៏ដូចជាសម្រាប់អ្នកដែលបានធ្លាក់ដល់ចំណុចសូន្យ ដោយសារតែការមិនស្ដាប់បង្គាប់ព្រះ។

កណ្ឌគម្ពីរយ៉ូណាសបាននិយាយសង្កត់ធ្ងន់អំពីការផ្ដត់ផ្គង់របស់ព្រះច្រើនជាងបញ្ហារបស់លោក យ៉ូណាស។ ព្រះអង្គបានប្រើមធ្យោបាយលើសពីធម្មតា ដើម្បីសង្គ្រោះលោក យ៉ូណាស ឲ្យរួចពីបាប និងការមិនស្ដាប់បង្គាប់របស់គាត់។ គាត់បានទទួលស្គាល់ថា “ទ្រង់បានបោះទូលបង្គំទៅក្នុងទីជំរៅ គឺចុះទៅក្នុងផ្ទៃនៃសមុទ្រ”(យ៉ូណាស ២:៤)។ ជាការពិតណាស់ ពួកនាវិកគឺជាអ្នកបោះលោក យ៉ូណាស



Jonah - Gods Most Reluctant Prophet - 1.4.indd 17 9/6/26 9:03 in the morning

ចេញពីសំពៅ តែលោក យ៉ូណាស បានទទួលស្គាល់ថា រឿងដែលបានកើតឡើងនោះស្ថិតនៅក្នុងព្រះហស្តនៃការគ្រប់គ្រងរបស់ព្រះអង្គ ហើយពួកនាវិកគឺជាឧបករណ៍ដែលព្រះអង្គបានប្រើប៉ុណ្ណោះ។ ព្រះអង្គបានដេញតាមគាត់ ហើយឲ្យគេបោះគាត់ចូលទៅក្នុងសមុទ្រដែលមានរលកធំៗ ដើម្បីឲ្យគាត់អាចទៅដល់ចំណុចដែលគាត់អាចនិយាយថា «ទូលបង្គំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយព្រោះទុក្ខលំបាករបស់ទូលបង្គំ ទ្រង់ក៏បានឆ្លើយមកទូលបង្គំហើយ»។

ជាងនេះទៅទៀត ក្នុងពោះត្រីធំនោះ លោកហោរាក៏បានស្គាល់ការឈឺចាប់នៃការដាច់ចេញពីព្រះ ឬ «ត្រូវបោះចោលចេញពីចំពោះព្រះនេត្រទ្រង់»(យ៉ូណាស ២:៥)។ សម្រាប់លោក យ៉ូណាស ការឈឺចាប់ខាងរូបកាយ ដែលស្ទើរលង់ទឹកសមុទ្រស្លាប់ និងត្រូវត្រីធំលេបចូលក្នុងពោះ គឺមិនអាចប្រៀបផ្ទឹមនឹងការដាច់ចេញពីព្រះវត្តមាននៃព្រះវរបិតារបស់គាត់ដែលគង់នៅស្ថានសួគ៌ឡើយ។ លោក យ៉ូណាស ស្គាល់សេចក្តីស្រឡាញ់របស់ព្រះ គាត់ដឹងថា ការនៅជាប់ក្នុងព្រះវត្តមានព្រះមានលក្ខណៈដូចម្តេច។ គាត់អាចយល់អត្ថន័យនៃការដាច់ចេញពីព្រះ ទោះគាត់បានដឹងអំពីផលវិបាកនៃការដាច់ចេញពីព្រះហើយក៏ដោយ ក៏គាត់នៅតែសម្រេចចិត្តដាច់ចេញពីព្រះ។

នេះជាមេរៀនដ៏មានតម្លៃសម្រាប់យើង។ ពេលណាយើងវង្វេងចេញពីព្រះអង្គ ព្រះអង្គយាងមករកយើងនៅក្នុងខ្យល់ព្យុះ ឬក្នុងជ្រលងភ្នំ ដោយកែប្រែកាលៈទេសៈរបស់យើង ដើម្បីទាក់ទាញចំណាប់

អារម្មណ៍របស់យើង ហើយក៏បានអនុញ្ញាតឲ្យយើងមានអារម្មណ៍ឯកោ និងដាច់ចេញពីអ្វីៗគ្រប់យ៉ាង ដើម្បីឲ្យយើងអាចនិយាយថា «ខ្ញុំមិនត្រូវបន្តរស់នៅដូចនេះទៀតទេ។ ព្រះអម្ចាស់មិនសព្វព្រះទ័យឲ្យខ្ញុំធ្វើដូចនេះទេ។ ខ្ញុំមិនអាចរំដោះខ្លួនឯងចេញពីបញ្ហានេះបានទេ តែព្រះអង្គអាច»។

ថ្ងៃនេះ អ្នកប្រហែលជាកំពុងជម្នះអារម្មណ៍ដែលបរាជ័យ និងស្តាយក្រោយក្នុងជម្រៅចិត្តអ្នក។ អ្នកកំពុងរត់គេចពីព្រះអង្គ។ អ្នកមិនស្តាប់បង្គាប់ព្រះសូរសៀងដ៏ច្បាស់លាស់របស់ព្រះ ហើយព្យាយាមលាក់ខ្លួន។ តែរឿងរបស់អ្នកមិនចាំបាច់ត្រូវបញ្ចប់ត្រឹមចំណុចនេះទេ។ ដោយព្រះគុណ និងសេចក្តីសប្បុរស ព្រះអង្គបានប្តេជ្ញាថា នឹងជួយសង្គ្រោះអ្នក ហើយសម្រេចកិច្ចការដែលព្រះអង្គបានចាប់ផ្តើមក្នុងជីវិតអ្នក (ភីលីព ១:៦)។ ក្នុងជីវិតគ្រីស្ទបរិស័ទ យើងតែងតែចាំបាច់ត្រូវប្រែចិត្ត តែគ្មានហេតុផលដែលត្រូវអស់សង្ឃឹមនោះទេ។

កាលលោក យ៉ូណាសបានទៅដល់ដីគោក គឺមិនមែនដោយសារគាត់សមនឹងរួចជីវិតនោះទេ។ តែដោយសារព្រះគុណព្រះអង្គប៉ុណ្ណោះ។ ដូចគ្នានេះដែរ មានតែព្រះទេដែលយាងមករកយើង ពេលយើងនៅជាប់ក្នុងបាប និងការមិនស្តាប់បង្គាប់ ដើម្បីឲ្យព្រះអង្គអាចសម្អាត សង្គ្រោះ និងស្អាងយើងឡើងវិញឲ្យត្រូវនឹងគោលបំណងរបស់ព្រះអង្គ។ តើអ្នកបានឃើញដីគោកហើយឬនៅ នៅថ្ងៃនេះ?



Jonah - Gods Most Reluctant Prophet - 1.4.indd 19 9/6/26 9:03 in the morning

*ព្រះគម្ពីរសញ្ជឹងគិត៖ យ៉ូណាស ២*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៨១-៨៣ និង ១ពេត្រុស ១*

# ប្រកាសអំពីសេចក្ដីមេត្តារបស់ព្រះ

*«ចំណេរមក ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់យ៉ូណាសម្តងទៀតថា ចូរក្រោកឡើងទៅឯនីនីវេ ជាក្រុងធំ ហើយប៉ាវប្រកាសដល់គេតាមសេចក្តីដែលអញនឹងបង្គាប់ ដូច្នេះយ៉ូណាសក៏ក្រោកឡើងទៅឯក្រុងនីនីវេតាមព្រះបន្ទូលនៃព្រះយេហូវ៉ា» (យ៉ូណាស ៣:១-៣)។*

ព្រះទ្រង់ជាព្រះដែលផ្តល់ឱកាសលើកទី២។

លោក យ៉ូណាស បានរត់គេចពីព្រះអម្ចាស់ ក្នុងការឆ្លើយតបចំពោះការត្រាស់ហៅរបស់ព្រះអង្គឲ្យទៅព្រមានទីក្រុងនីនីវេ អំពីការជំនុំជម្រះដែលនឹងត្រូវមក។ ប៉ុន្តែ នៅពេលដែលព្រះអង្គត្រាស់ហៅគាត់ម្តងទៀត គាត់មិនបានរត់គេចទៀតទេ។ គាត់បានស្គាល់កំហុសខ្លួនឯង ហើយបានស្គាល់ព្រះគុណដែលព្រះបានបង្ហាញដល់គាត់ ដូចនេះ គាត់ហាក់ដូចជាមានចិត្តអន្ទះសាចង់ប្រកាសព្រះរាជសារពេលដែលគាត់មានឱកាស។ ពេលយើងអានដល់ចំណុចដែលលោកយ៉ូណាស ប្រកាសដល់ប្រជាជនក្នុងទីក្រុងឲ្យប្រែចិត្តចេញពីអំពើបាប



Jonah - Gods Most Reluctant Prophet - 1.4.indd 21 9/6/26 9:03 in the morning

យើងអាចស្រមៃអំពីទម្ងន់នៃបទពិសោធន៍របស់គាត់ នៅពេលដែលគាត់ចាប់ផ្តើមប្រកាសអំពីផលវិបាកនៃការមិនស្តាប់បង្គាប់ព្រះ។ គាត់បាននាំការព្រមានមក ព្រមទាំងទីបន្ទាល់ផ្ទាល់ខ្លួនអំពីការពិតដែលថា ព្រះអង្គស្ម័គ្រព្រះទ័យ និងអាចសង្គ្រោះមនុស្សមានបាប ឲ្យរួចពីកាលៈទេសៈដែលធ្ងន់ធ្ងរបំផុត។ ទោះក្រោយមក គាត់បានបង្ហាញចេញនូវអាកប្បកិរិយាដែលមិនបានឱបក្រសោបយកទំហំនៃព្រះគុណព្រះទាំងស្រុងក៏ដោយ (យ៉ូណាស ៤:១-៣) ក៏សេចក្តីមេត្តាដែលព្រះអង្គបានបង្ហាញដល់គាត់ ពិតជាបាននាំឲ្យអ្នកក្រុងនីនីវេបានឮព្រះរាជសារព្រះអង្គ។ ព្រះដែលបានប្រទានឱកាសទីពីរតាមរយៈត្រីធំ ឥឡូវនេះព្រះអង្គក៏បានប្រទានឱកាសទីពីរដល់មនុស្សទាំងប្រុសស្រីក្នុងទីក្រុង ដែលបានងាកបែរចេញពីព្រះអង្គដោយស្ម័គ្រពីចិត្ត។

តើអ្នកឃើញទេ ព្រះអង្គជាព្រះដែលប្រទានឱកាសលើកទី២ (ហើយទី៣ និងទី៤ទៀតផង)? តើអ្នកឃើញទេ អ្នកមិនអាចរត់គេចពីសេចក្តីមេត្តា ឬស្គាល់ជម្រៅនៃព្រះគុណរបស់ព្រះអង្គឡើយ? បើអ្នកបានដឹងមែន អ្នកប្រាកដជានាំដំណឹងល្អទៅប្រាប់អ្នកដទៃមិនខាន។ ហើយការប្រព្រឹត្តដូចនេះ នឹងបានឆ្លុះបញ្ចាំងអំពីសេចក្តីមេត្តាដែលអ្នកបានទទួល។ បើគ្រីស្ទានបង្ហាញចេញនូវអត្តចរិតកាចគ្មានក្តីអាណិត ហើយតឹងរ៉ឹងជ្រុលពេក ពេលដែលពួកគេនិយាយអំពីជំនឿរបស់ខ្លួន ការនេះបានបង្ហាញថា ចិត្តរបស់ពួកគេមិនបានបន្ទន់ទាំងស្រុង ដោយសេចក្តីមេត្តា ព្រះគុណ និងសេចក្តីស្រឡាញ់របស់



Jonah - Gods Most Reluctant Prophet - 1.4.indd 22 9/6/26 9:03 in the morning

ព្រះនៅឡើយទេ។ ម្យ៉ាងទៀត ពេលណាពាក្យសម្ដី និងសកម្មភាពរបស់ពួកគេបានឆ្លុះបញ្ចាំង អំពីលក្ខណៈនៃសេចក្តីមេត្តារបស់ព្រះ ដែលមានភាពទាក់ទាញ និងមានការជំរុញចិត្ត ការនេះបានបង្ហាញច្បាស់ថា ពួកគេបានដកពិសោធន៍ជាមួយសេចក្តីមេត្តានោះដោយផ្ទាល់ហើយ។

លោក ឆាល វេសលី (Charles Wesley) ជាអ្នកនិពន្ធបទចម្រៀងទំនុកបរិសុទ្ធមានចំណងជើងថា «សេចក្តីមេត្តារបស់ព្រះបានឈ្នះចិត្តខ្ញុំ»។ គាត់បានប្រកាសម្តងហើយម្តងទៀតក្នុងបទចម្រៀងនេះថា ៖ ឱជម្រៅនៃសេចក្តីមេត្តារបស់ព្រះ! តើព្រះអង្គនៅតែមានសេចក្តីមេត្តាសម្រាប់ខ្ញុំទេ? តើព្រះនៃខ្ញុំបានដកសេចក្តីក្រោធចេញទេ? តើព្រះអង្គបានទុកជីវិតឲ្យខ្ញុំជាមនុស្សដែលមានបាបធ្ងន់ជាងគេទេ?

ខ្ញុំបានប្រឆាំងព្រះគុណព្រះអង្គជាយូរមកហើយ ដោយមិនស្តាប់បង្គាប់ព្រះអង្គ និងមិនអើពើចំពោះព្រះសូរសៀងព្រះអង្គ និងបានធ្វើឲ្យព្រះអង្គឈឺចាប់ព្រះទ័យម្តងហើយម្តងទៀត ដោយសារកំហុសជាច្រើនរាប់មិនអស់។ តែព្រះអង្គសង្គ្រោះបានឈរនៅពីមុខខ្ញុំ ដោយលាព្រះហស្តដែលមានរបួសមករកខ្ញុំ។ ឥឡូវនេះ ខ្ញុំដឹងថា ព្រះអង្គជាតួនៃសេចក្តីស្រឡាញ់។ ខ្ញុំអាចដឹងបាន។ ទោះព្រះយេស៊ូវបានព្រះកន្សែងដោយសារបាបរបស់ខ្ញុំ ក៏ព្រះអង្គនៅតែស្រឡាញ់ខ្ញុំ។

ឥឡូវនេះ ចូរជញ្ជឹងគិតអំពីសេចក្តីមេត្តាដែលព្រះមានចំពោះអ្នក ដោយនាំអ្នកឲ្យមានសេចក្តីជំនឿ ហើយនៅបន្តមានព្រះទ័យ



Jonah - Gods Most Reluctant Prophet - 1.4.indd 23 9/6/26 9:03 in the morning

អត់ធ្មត់ចំពោះអ្នក និងអត់ទោសឲ្យអ្នក។ ចូរឲ្យភាពស្ងប់ស្ងែងដែលអ្នកមានចំពោះអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នកបានបណ្ដាលចិត្តអ្នកឲ្យចែកចាយដល់អ្នកដទៃ អំពីសេចក្ដីស្រឡាញ់ដ៏ជួយសង្គ្រោះរបស់ព្រះអង្គ។ ហើយបើសិនជាមាននរណាម្នាក់ដែលអ្នកស្គាល់ តែអ្នកមិនបានបង្ហាញសេចក្ដីមេត្តារបស់ព្រះ ឬចែកចាយសេចក្ដីមេត្តារបស់ព្រះអង្គដល់ពួកគេនៅពេលដែលមានឱកាស ចូរអធិស្ឋានសូមឱកាសចែកចាយម្ដងទៀត ហើយឆក់យកឱកាសនោះចុះ។

*ព្រះគម្ពីរសញ្ចឹងគិត៖ ទំនុកតម្កើង ៣០*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៨៤-៨៦ និង ១ពេត្រុស ២*

Jonah - Gods Most Reluctant Prophet - 1.4.indd 24 9/6/26 9:03 in the morning

# ការប្រាប់ឲ្យប្រែចិត្ត

*«ពួកបណ្ដាជននៅក្រុងនីនីវេ គេក៏ជឿព្រះអង្គ។ ដូច្នេះ គេប្រកាសឲ្យមានពេលតមអត់ ហើយស្លៀកសំពត់ធ្មៃ ចាប់តាំងពីអ្នកធំបំផុត រហូតដល់អ្នកតូចជាងគេ។ ដំណឹងនោះក៏ឮទៅដល់ស្ដេចនៃក្រុងនីនីវេ រួចទ្រង់ក្រោកចាកពីបល្ល័ង្ក ដោះព្រះពស្ត្រចេញ ហើយគ្រលុំអង្គដោយសំពត់ធ្មៃ ទៅគង់នៅក្នុងផេះវិញ» (យ៉ូណាស ៣:៥-៦)។*

សូមអ្នកស្រមៃថា ប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីរបស់អ្នកធ្វើការអំពាវនាវដល់ប្រជាជនទូទាំងប្រទេស ឲ្យលះបង់ចោលអំពើហិង្សា ងាកបែរចេញពីសេចក្ដីអាក្រក់ ហើយស្វែងរកសេចក្ដីមេត្តារបស់ព្រះ ដើម្បីឲ្យព្រះអង្គអាចសង្គ្រោះពួកគេឲ្យរួចផុតពីការជំនុំជម្រះរបស់ព្រះអង្គ? នេះជារឿងដែលបានកើតឡើង នៅទីក្រុងនីនីវេ នៅចំពោះមុខលោកយ៉ូណាស។

នេះជារឿងគួរឲ្យកត់សម្គាល់ណាស់ នៅពេលដែលអ្នកក្រុងនីនីវេបានទទួលជឿព្រះភ្លាមៗ ដោយការស្រុះស្រួលគ្នាទាំងស្រុង។ ពេលដែលពួកគេបានឮការព្រមានរបស់លោក យ៉ូណាស អំពីការជំនុំជម្រះដែលត្រូវមកដល់ ពួកគេក៏បានឆ្លើយតបទាំងអស់គ្នា អស់ពីចិត្ត



Jonah - Gods Most Reluctant Prophet - 1.4.indd 25 9/6/26 9:03 in the morning

ដោយការស្លៀកសំពត់ធ្មៃគឺជាភស្តុតាងនៃការទទួលស្គាល់កំហុស។ ការឆ្លើយតបជាសាធារណៈនេះ ក៏ស្របនឹងការឆ្លើយតបរបស់ស្តេចផងដែរ។ ស្តេចក៏បានផ្លាស់សម្លៀកបំពាក់ ដោយជំនួសអាវវែងរបស់ក្សត្រ ដោយសំពត់ធ្មៃវិញ ហើយក៏បានផ្លាស់ប្តូរទីកន្លែង ដោយចុះពីបល្ល័ង្កទៅជាអង្គុយនៅក្នុងផេះវិញ រួចទ្រង់ក៏បានផ្លាស់ប្តូរពាក្យសម្តី ដោយចេញប្រកាសអំពីការប្រែចិត្ត។

ការនេះខុសពីមនុស្សជាច្រើននៅសម័យព្រះយេស៊ូវ ហើយក៏ប្រហែលនៅសម័យយើងផងដែរ។ គឺដូចដែលព្រះយេស៊ូវបានបង្រៀនដោយផ្ទាល់ថា ប្រជាជននៅទីក្រុងនីនីវេបានប្រែចិត្ត នៅពេលបានឮលោក យ៉ូណាស ប្រកាសព្រះបន្ទូល ប៉ុន្តែមនុស្សជាច្រើនរាប់មិនអស់ដែលព្រះអង្គបានបង្រៀនមិនបានជឿទេថា «នៅទីនេះ មាន១អង្គដ៏វិសេសលើសជាងលោក យ៉ូណាស ទៅទៀត»(លូកា ១១:៣២)។ ពួកគេបានបដិសេធន៍មិនព្រមទទួលជឿដូចស្តេចនីនីវេ ដែលបានមានបន្ទូលថា «ត្រូវឲ្យគេលាកចេញពីផ្លូវអាក្រក់របស់គេរៀងខ្លួន ហើយពីការច្រឡោតដែលនៅដៃខ្លួនផង ប្រហែលជាព្រះទ្រង់នឹងប្រែព្រះហឫទ័យ ហើយផ្លាស់គំនិត ព្រមលាកចេញពីសេចក្តីក្រោធដ៏សហ័សរបស់ទ្រង់ ដើម្បីមិនឲ្យយើងត្រូវវិនាសទៅទេដឹង»(យ៉ូណាស ៣:៨-៩)។ ស្តេចមិនបានជ្រាបច្បាស់ថា ការប្រែចិត្តរបស់អ្នកក្រុងនីនីវេប្រាកដជានាំឲ្យព្រះអម្ចាស់លើកលែងទោសឲ្យពួកគេនោះឡើយ។

រឿងនេះបានរំឭកយើងថា សូម្បីតែការប្រែចិត្តក៏មិនអាចជាការ



Jonah - Gods Most Reluctant Prophet - 1.4.indd 26 9/6/26 9:03 in the morning

ទាមទារឲ្យព្រះទ្រង់ទទួលយកយើងឡើយ។ បានសេចក្តីថា ពួកគេត្រូវតែពឹងផ្អែកទៅលើព្រះគុណរបស់ព្រះតែមួយមុខប៉ុណ្ណោះ។ ការប្រែចិត្តមានភាពចាំបាច់ ចំពោះការអត់ទោសបាប តែមិនបានធ្វើឲ្យយើងស័ក្តិសមនឹងទទួលការអត់ទោសបាបនោះទេ។ គឺដូចដែលកូនពៅវង្វេងបាននិយាយ ដោយការប្រែចិត្តពិតប្រាកដថា «អញនឹងក្រោកឡើង ទៅនិយាយនឹងគាត់ថា លោកឪពុក ខ្ញុំបានធ្វើបាបនឹងព្រះ ហើយនឹងលោកឪពុកមែន។ ខ្ញុំនេះមិនគួរឲ្យគេហៅជាកូនលោកឪពុកទៀតទេ សូមទទួលខ្ញុំទុកដូចជាជើងឈ្នួលលោកឪពុកវិញចុះ»(លូកា ១៥:១៨-១៩)។ ការប្រែចិត្តចាប់ផ្តើម ដោយការទទួលស្គាល់ថា យើងពិតជាស័ក្តិសមនឹងទទួលការជំនុំជម្រះរបស់ព្រះ និងទទួលស្គាល់ដោយបើកចំហ និងអស់ពីចិត្តថា យើងពិតជាត្រូវការសេចក្តីមេត្តារបស់ព្រះអង្គ។

ដោយសារព្រះអង្គដែលវិសេសលើសលោក យ៉ូណាស គង់នៅជាមួយយើងជាស្រេច យើងអាចដឹង និងប្រកាសថា ការប្រែចិត្តតែងតែទទួលបានការអត់ទោសបាប ព្រោះ «គ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ»(រ៉ូម ១០:១៣)។ ប៉ុន្តែ អ្វីដែលយើងគួរតែរៀនសូត្រពីស្តេចអង្គនោះគឺ យើងមិនអាចបញ្ជាព្រះហស្តរបស់ព្រះ ដោយការប្រែចិត្ត ឬការស្តាប់បង្គាប់របស់យើងទេ ហើយការប្រែចិត្តពិតប្រាកដមិនមែនមានតែសម្បកក្រៅ តែត្រូវចេញពីក្នុងចិត្ត ដោយយើងត្រូវកែប្រែអាកប្បកិរិយារបស់យើង។



Jonah - Gods Most Reluctant Prophet - 1.4.indd 27 9/6/26 9:03 in the morning

នេះជាមេរៀន ដែលយើងត្រូវអនុវត្តតាមក្នុងជីវិតជាគ្រីស្ទបរិស័ទ គឺដូចដែលលោក ម៉ាទីន លូស័រ (Martin Luther) បានមានប្រសាសន៍ថា «ពេលណាព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលជាគ្រូរបស់យើងប្រាប់យើងថា «ចូរប្រែចិត្ត» នោះគឺព្រះអង្គមានគោលបំណងឲ្យជីវិតអ្នកជឿទាំងមូលមានការកែប្រែ»។[២]

*ព្រះគម្ពីរសញ្ជឹងគិត៖ លូកា ១១:២៩-៣២*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៨៧-៨៨ និង ១ពេត្រុស ៤*

២ The Ninety-Five Theses, First Thesis



Jonah - Gods Most Reluctant Prophet - 1.4.indd 28 9/6/26 9:03 in the morning

# ព្រះនៃយើងមិនប្រែប្រួល

*«ព្រះទ្រង់ទតឃើញការទាំងប៉ុន្មានដែលគេប្រព្រឹត្តនោះ គឺដែលគេបាន លាកចេញពីផ្លូវអាក្រក់របស់គេ រួចព្រះក៏ប្រែគំនិតពីការអាក្រក់ ដែលទ្រង់ បានគំរាមថា នឹងធ្វើដល់គេ ហើយទ្រង់លែងធ្វើទៅ»(យ៉ូណាស ៣:១០)។*

ព្រះគម្ពីរប៊ីបបានចែងយ៉ាងច្បាស់ថា ព្រះទ្រង់មិនដែលប្រែប្រួល ឡើយ។ ទន្ទឹមនឹងនោះ កណ្ឌគម្ពីរយ៉ូណាស ក៏បានបញ្ជាក់ផងដែរថា ព្រះអង្គអាច និងពិតជាបានផ្លាស់ប្តូរឥរិយាបថរបស់ព្រះអង្គ ចំពោះ ប្រជាជនទាំងនោះ និងផ្លាស់ប្តូររបៀបដែលព្រះអង្គប្រព្រឹត្តចំពោះ ពួកគេ។ តើធ្វើដូចម្តេចឲ្យយើងអាចយល់អំពីការបកស្រាយទាំងពីរ នេះ ដែលហាក់ដូចជាផ្ទុយគ្នា?

យើងក៏អាចមើលឃើញភាពតានតឹងដូចនេះនៅក្នុងកណ្ឌគម្ពីរ ផ្សេងទៀតផងដែរ។ កាលព្រះអង្គដោះស្រាយបញ្ហាជាមួយស្តេច សូល ព្រះអង្គមានបន្ទូលថា “អញស្តាយណាស់ដែលបានតាំងសូលឡើងឲ្យ ធ្វើជាស្តេច ដ្បិតបានងាកបែរចេញលែងតាមអញហើយ ក៏មិនបានធ្វើ តាមបង្គាប់របស់អញសោះ”(១សាំយ៉ូអែល ១៥:១១)។ ប៉ុន្តែ ក្នុងបទ

គម្ពីរបន្តបន្ទាប់ទៀត យើងឃើញថា «ទ្រង់មិនចេះកុហក ឬប្រែប្រួលឡើយ ដ្បិតទ្រង់មិនមែនជាមនុស្សដែលចេះប្រែប្រួលទេ»(ខ.២៩)។ ព្រះអង្គហាក់ដូចជាមានការស្ដាយក្រោយ ចំពោះការសម្រេចព្រះទ័យរបស់ព្រះអង្គ ប៉ុន្តែក្រោយមក ព្រះគម្ពីរបានចែងថា ព្រះអង្គមិនមានការស្ដាយក្រោយទេ។

ប៉ុន្តែ របៀបនៃការពិពណ៌នាទាំងពីរនេះ មិនមានភាពផ្ទុយគ្នាទេ។ ពេលណាព្រះគម្ពីរប៊ីបចែងថា ព្រះអង្គស្ដាយក្រោយ ឬបានកែប្រែព្រះទ័យ គឺព្រះគម្ពីរកំពុងប្រើភាសា ដើម្បីឲ្យយើងជាមនុស្សអាចយល់អំពីព្រះទ័យរបស់ព្រះអង្គបាន។ ការពិពណ៌នានេះ ហាក់ដូចជាបង្ហាញថា ព្រះអង្គមានការផ្លាស់ប្ដូរ ប៉ុន្តែអ្វីដែលពិតជាបានផ្លាស់ប្ដូរ គឺការប្រព្រឹត្តរបស់យើងជាមនុស្សទៅវិញទេ។ និយាយឲ្យងាយស្ដាប់ ស្ដេច សូល មិនមែនជាមនុស្សដូចកាលពីមុនទេ។ ទ្រង់បានបន្តមិនស្ដាប់បង្គាប់ព្រះអម្ចាស់ ហើយព្រះអង្គក៏បានឆ្លើយតបចំពោះកាលៈទេសៈដែលបានផ្លាស់ប្ដូរនោះ តាមរបៀបដែលសមស្របទាំងស្រុងនឹងចរិតលក្ខណៈរបស់ព្រះអង្គ។ ស្រដៀងគ្នានេះដែរ នៅក្នុងការឆ្លើយតបចំពោះការប្រកាសរបស់លោក យ៉ូណាស អ្នកក្រុងនីនីវេក៏បានផ្លាស់ប្ដូរការប្រព្រឹត្តរបស់ខ្លួន ដោយងាកចេញពីការអាក្រក់។ ព្រះអម្ចាស់តែងតែប្រឆាំងអំពើបាបជាប់ជានិច្ច ហើយសព្វព្រះទ័យឲ្យយើងប្រែចិត្ត និងមានជំនឿ ដូចនេះចរិតលក្ខណៈរបស់ព្រះអង្គមិនបានផ្លាស់ប្ដូរទេ។ ការព្រមានរបស់ព្រះអង្គ គឺបាន



Jonah - Gods Most Reluctant Prophet - 1.4.indd 30 9/6/26 9:03 in the morning

ធ្វើឡើងក្នុងគោលបំណង ដើម្បីដាស់តឿនមនុស្សដែលបានដើរផ្លូវខុស ឲ្យងាកមករកការប្រែចិត្តវិញ ហើយបើការប្រែចិត្តកើតមាន នោះព្រះអង្គក៏ឆ្លើយតប ដោយការអត់ទោសបាបផងដែរ។

ទាល់តែព្រះទ្រង់ឆ្លើយយ៉ាងដូចនេះ ទើបមនុស្សមានបាបដែលជឿព្រះយេស៊ូវអាចដឹងថា ព្រះអង្គសព្វព្រះទ័យនឹងអត់ទោសឲ្យយើង។ ដោយសារ «ព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ»(ហេព្រើរ ១៣:៨)។ នោះយើងអាចដឹងថា ពេលណាយើងចូលមករកព្រះអង្គ ដោយការសោកស្ដាយចំពោះកំហុសរបស់យើង និងដោយជំនឿដូចកូនក្មេង ព្រះអង្គនឹងទទួលយើងដោយសេចក្ដីអាណិត និងសេចក្ដីមេត្តា។ នេះជាចារិតលក្ខណៈរបស់ព្រះអង្គ ហើយព្រះអង្គមិនប្រែប្រួលឡើយ។

តាមទស្សនៈរបស់យើង ព្រះអង្គហាក់ដូចជាផ្លាស់ប្ដូរព្រះទ័យ ប៉ុន្តែព្រះអង្គនៅតែធ្វើតាមពាក្យគ្រប់ម៉ាត់ ដែលព្រះអង្គបានមានបន្ទូលហើយ។ យើងអាចមានទំនុកចិត្ត និងក្ដីអំណរនៅថ្ងៃនេះ ផ្អែកទៅលើសេចក្ដីពិតនេះ ខណៈពេលដែលលោកីយ៍នៅតែមានការផ្លាស់ប្ដូរជានិច្ច ហើយសូម្បីតែមនុស្សល្អបំផុត ក៏មិនអាចគោរពពាក្យសម្ដីរបស់ខ្លួនឯងបានគ្រប់ពេលដែរ។

*ព្រះគម្ពីរសញ្ជឹងគិត៖ យ៉ូណាស ៣*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៨៩-៩០ និង ១ពេត្រុស ៤*



Jonah - Gods Most Reluctant Prophet - 1.4.indd 31 9/6/26 9:03 in the morning

Jonah -  Gods Most Reluctant Prophet - 1.4.indd   32    9/6/26   9:03 in the morning

# ស្របតាមផែនការរបស់ព្រះ

*«ព្រះទ្រង់ទតឃើញការទាំងប៉ុន្មានដែលគេប្រព្រឹត្តនោះ គឺដែលគេបានលាកចេញពីផ្លូវអាក្រក់របស់គេ រួចព្រះក៏ប្រែគំនិតពីការអាក្រក់ ដែលទ្រង់បានគំរាមថា នឹងធ្វើដល់គេ ហើយទ្រង់លែងធ្វើទៅ។ តែការនោះជាទីទំនាស់ចិត្តដល់យ៉ូណាសយ៉ាងក្រៃលែង ហើយលោកក៏ខឹង» (យ៉ូណាស ៣:១០-៤:១)។*

ពេលខ្លះ សូម្បីតែពួកហោរាក៏នៅមានមេរៀនជាច្រើន ដែលត្រូវរៀនសូត្រ។

បន្ទាប់ពីលោក យ៉ូណាស បានចូលទៅក្នុងពោះត្រីធំអស់បីថ្ងៃ គាត់បានឈប់ប្រឆាំងព្រះរាជបញ្ជារបស់ព្រះអង្គទៀត ប៉ុន្តែគាត់នៅតែមានអារម្មណ៍មិនសប្បាយចិត្តនៅក្នុងការស្តាប់បង្គាប់ ដោយគាត់នៅតែប្រឆាំងព្រះគុណរបស់ព្រះ។ គាត់បានព្យាយាមរត់គេចពីបំណងព្រះទ័យដែលព្រះអង្គមានសម្រាប់គាត់ តែគាត់នៅតែបានទៅដល់កន្លែងដែលព្រះអង្គឲ្យគាត់ទៅ ហើយក៏បានប្រកាសអំពីអ្វីដែលព្រះអង្គបានបង្គាប់ឲ្យប្រកាសហើយដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែមានការពេញចិត្តចំពោះផែនការប្រកបដោយ



Jonah - Gods Most Reluctant Prophet - 1.4.indd 33 9/6/26 9:03 in the morning

ព្រះគុណ ដែលព្រះអង្គមានសម្រាប់ទីក្រុងនីនីវេ។ ភាពផុសផុល បានផ្ទុះឡើងក្នុងទីក្រុង ដែលធ្លាប់តែមានភាពរឹងទទឹងទាំងស្រុង ចំពោះព្រះនៃសាសន៍អ៊ីស្រាអែល ហើយហោរារូបនេះក៏បានឆ្លើយតប ដោយកំហឹងចំពោះព្រះរបស់ខ្លួន!

ប៉ុន្តែ ទោះលោក យ៉ូណាស ជាមនុស្សឆេវឆាវ និងមានចិត្តចង្អៀតចង្អល់ ហើយឆ្លើយតបដោយមិនត្រឹមត្រូវ ចំពោះសេចក្តីសប្បុរសរបស់ព្រះក៏ដោយ ក៏ព្រះអង្គមិនបានបោះបង់ចោលគាត់ឡើយ។ ព្រះអង្គបានប្រទានសត្វត្រីធំមួយឲ្យសង្គ្រោះគាត់ឲ្យរួចផុតពីការមិនស្តាប់បង្គាប់ ហើយព្រះអង្គក៏អាចប្រទានសត្វតោធំមួយក្បាលមកឲ្យស៊ីគាត់ ដោយគ្មាននរណាអាចកាត់ទោសព្រះអង្គឡើយ។ ប៉ុន្តែ ព្រះអង្គមិនបានធ្វើដូចនេះទេ ព្រោះព្រះអង្គមានព្រះគុណ និងសេចក្តីអាណិត។ ព្រះអង្គបានប្រព្រឹត្តចំពោះលោក យ៉ូណាស ដោយព្រះទ័យអត់ធ្មត់ និងសេចក្តីសប្បុរស ដើម្បីឲ្យគាត់ភ្ញាក់ខ្លួនទទួលស្គាល់កំហុស ពោលគឺដើម្បីឲ្យគាត់ផ្លាស់ប្តូរគំនិត។

ការឆ្លើយតបរបស់លោក យ៉ូណាស ចំពោះការប្រែចិត្តរបស់អ្នកក្រុងនីនីវេ មានលក្ខណៈចម្លែកក្នុងនាមគាត់ជាអ្នកប្រកាសព្រះបន្ទូល។ យើងប្រហែលជារំពឹងថា គាត់មានការដឹងគុណ ដែលព្រះបានសម្រេចព្រះទ័យមិនបោះបង់គាត់ចោល តែព្រះអង្គបានប្រទានគាត់នូវឯកសិទ្ធិនៅក្នុងការបម្រើព្រះអង្គ។ តែផ្ទុយទៅវិញ ការប្រែចិត្តរបស់ប្រជាជននៅទីក្រុង «ជាទីទំនាស់ចិត្តដល់យ៉ូណាសយ៉ាងក្រៃ



Jonah - Gods Most Reluctant Prophet - 1.4.indd 34 9/6/26 9:03 in the morning

លែង»។ គេអាចបកប្រែឃ្លានេះ ដោយត្រង់ៗថា «ការនេះគឺជាការអាក្រក់ ចំពោះលោក យ៉ូណាស គឺអាក្រក់ក្រៃលែង»។ គ្រោះមហន្តរាយដែលគាត់រំពឹងថានឹងកើតឡើង ឬការជំនុំជម្រះ ដែលគាត់គិត និងសង្ឃឹមថានឹងធ្លាក់មកលើទីក្រុងនីនីវេ មិនបានកើតឡើងទេ ជាហេតុនាំឲ្យគាត់មានចិត្តក្តៅក្រហាយយ៉ាងខ្លាំង។

ស្តាប់មើលទៅ ទង្វើរបស់គាត់ហាក់ដូចជាមិនអាចទទួលយកបានទាល់តែសោះ ប៉ុន្តែបើយើងពិនិត្យមើលចិត្តគំនិត និងការឆ្លើយតបរបស់យើងចំពោះបញ្ហា យើងអាចដឹងថា យើងមិនខុសពីលោកយ៉ូណាស ទេ។ យើងប្រហែលជាទៅកន្លែងដែលព្រះអង្គប្រាប់ឲ្យយើងទៅ និយាយអ្វីដែលព្រះអង្គប្រាប់ឲ្យយើងនិយាយ ហើយយើងប្រហែលមានភាពសមស្របនឹងការបង្គាប់ទាំងអស់របស់ព្រះអង្គតែសម្បកក្រៅទេ ប៉ុន្តែនៅក្នុងស្នូលនៃជីវិតយើង។ យើងប្រហែលមានចិត្តដែលមិនសមស្របនឹងផែនការរបស់ព្រះអង្គ ដែលកំពុងបង្ហាញចេញមក។ យើងប្រហែលចង់ឲ្យការជំនុំជម្រះធ្លាក់មកលើនរណាម្នាក់ ជាជាងឲ្យគាត់ទទួលសេចក្តីមេត្តាពីព្រះ។ យើងប្រហែលមិនពេញចិត្ត ពេលអ្នកដទៃទទួលព្រះពរ តាមរបៀបដែលព្រះអង្គមិនបានប្រទានពរយើង ឬពួកគេទទួលព្រះពរ ដោយមិនបានបង្ហាញការប្តេជ្ញាចិត្តចំពោះបេសកកម្មរបស់ព្រះអង្គ ដូចដែលយើងបានបង្ហាញនោះទេ។ យើងប្រហែលជាចង់ប្រាប់ព្រះ អំពីរបៀបដែលព្រះអង្គត្រូវរៀបចំអ្វីគ្រប់យ៉ាងក្នុងពិភពលោករបស់ព្រះអង្គ។



Jonah - Gods Most Reluctant Prophet - 1.4.indd 35 9/6/26 9:03 in the morning

តើធ្វើដូចម្តេចឲ្យយើងអាចមានសេចក្តីអាណិតដូចព្រះអង្គ ហើយចេញទៅធ្វើបេសកកម្មថ្វាយព្រះអង្គ ដោយក្តីអំណរ? ចូរយើងគ្រាន់តែចាំថា យើងមិនល្អជាងអ្នកដទៃទេ ឬមានភាពសក្តិសមនឹងទទួលសេចក្តីក្រោធតិចជាងគេ ហើយក៏មិនសក្តិសមនឹងទទួលសេចក្តីសប្បុរសរបស់ព្រះអង្គ ច្រើនជាងគេដែរ។ ឈើឆ្កាងបានបង្ហាញសេចក្តីមេត្តារបស់ព្រះ ហើយក៏បានធ្វើឲ្យយើងបន្ទាបខ្លួន និងមានសេចក្តីអាណិត និងព្រះគុណ ដែលបាននាំព្រះរាជបុត្រាព្រះអង្គទៅកាលវ៉ារី។ តើអ្នកកំពុងពិបាករស់នៅ ដោយសេចក្តីអាណិតដូចនេះចំពោះអ្នកដទៃឬទេ? ចូរមើលទៅឈើឆ្កាង ហើយសូមព្រះអម្ចាស់បង្រៀនអ្នក អំពីសេចក្តីអ្វីដែលព្រះអង្គបានបង្រៀនលោក យ៉ូណាស។

*ព្រះគម្ពីរសញ្ជឹងគិត៖ កូឡុស ១:២១-២៩*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៩១-៩៣ និង ១ពេត្រុស ៥*



Jonah - Gods Most Reluctant Prophet - 1.4.indd 36 9/6/26 9:03 in the morning

# អ្នកបម្រើដែលមិនស័ក្តិសម
# របស់ព្រះ

*«រួចលោកអធិស្ឋានដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ តើមិនមែនជាសេចក្តីនេះឯងដែលទូលបង្គំបានថា ក្នុងកាលដែលទូលបង្គំនៅឯស្រុករបស់ទូលបង្គំនៅឡើយទេឬអី គឺដោយហេតុនោះបានជាទូលបង្គំខំរត់ទៅឯក្រុងតើស៊ីសវិញ ពីព្រោះទូលបង្គំបានដឹងថា ទ្រង់ជាព្រះដ៏ប្រកបដោយករុណាគុណ ក៏មានព្រះហឫទ័យអាណិតអាសូរ ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរសជាបរិបូរ ក៏តែងតែប្រែគំនិតចេញពីការអាក្រក់ផង... តែព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលតបនឹងលោកថា ការដែលឯងខឹងដូច្នេះតើគួរឬ?» (យ៉ូណាស ៤:២,៤)។*

ពេលណាក្មេងៗធ្វើអ្វីខុស ពួកគេច្រើនតែស្វែងរកការអត់ទោសពីឪពុកម្តាយ ប៉ុន្តែពេលដែលឪពុកម្តាយបានអត់ទោសឲ្យពួកគេហើយ ពួកគេក៏បាននិយាយថា «កូនដឹងថាកូនបានធ្វើខុស ប៉ុន្តែ...កូនបានធ្វើដោយហេតុផលដ៏ល្អឥតខ្ចោះ»។ យើងឃើញថា ពួកគេបានដោះសាតាមរបៀបស្រដៀងនឹងហោរា យ៉ូណាស ផងដែរ។ ព្រះទ្រង់បានអត់



Jonah - Gods Most Reluctant Prophet - 1.4.indd 37 9/6/26 9:03 in the morning

ទោសឲ្យគាត់ លើកគាត់ឡើង ហើយនាំគាត់ឲ្យដើរផ្លូវត្រូវវិញ ប៉ុន្តែគាត់នៅតែព្យាយាមលើកហេតុផលការពារការមិនស្តាប់បង្គាប់របស់គាត់។ គាត់នៅតែមានកំហឹង និងប្រកែកជាមួយព្រះអង្គ ខណៈពេលដែលគាត់អធិស្ឋាន ដែលការធ្វើដូចនេះ គឺមិនងាយស្រួលទេ។

ចូរយើងកត់សម្គាល់ថា គាត់បានប្រើពាក្យ «ទូលបង្គំ» ប៉ុន្មានដងនៅក្នុងការប្រកែកជាមួយព្រះអង្គ។ គាត់បាននិយាយអំពីខ្លួនឯងច្រើនពេក ដូចនេះគាត់គិតអំពីខ្លួនឯងក្នុងចិត្តគាត់ច្រើនពេក ពេលដែលគាត់លើកយករឿងគាត់មកប្រកែកជាមួយព្រះអង្គ។ គាត់ទំនងគិតស្មានយ៉ាងល្ងង់ខ្លៅថា ផ្លូវរបស់គាត់ល្អជាងផ្លូវរបស់ព្រះអង្គ។

ការរអ៊ូរទាំរបស់លោក យ៉ូណាស ក៏បានចាក់ឫសចូលជ្រៅទៅក្នុងការមានស្តង់ដារពីរ។ ទោះគាត់ទើបតែបានទទួលសេចក្តីអាណិត និងសេចក្តីមេត្តារបស់ព្រះក៏ដោយ ក៏គាត់នៅតែមិនចង់ឲ្យព្រះអង្គបង្ហាញសេចក្តីមេត្តាដូចនោះដល់មនុស្ស ដែលគាត់មិនចង់ឲ្យព្រះអង្គប្រោសលោះ។

លោក យ៉ូណាស មានបញ្ហាធំមួយជាមួយព្រះគុណនៃការគ្រប់គ្រងរបស់ព្រះ។ គាត់ខឹង ព្រោះព្រះអង្គបានធ្វើតាមរបៀបដែលគាត់មិនយល់ ឬមិនគាំទ្រ។ ប៉ុន្តែ ព្រះអម្ចាស់បានប្រកាសតាំងពីយូរមកហើយថា «អញនឹងប្រោសដល់អ្នកណាដែលអញចង់ប្រោស ហើយនឹងផ្សាយសេចក្តីមេត្តាករុណាដល់អ្នកណាដែលអញចង់ផ្សាយឲ្យ»(និក្ខមនំ ៣៣:១៩)។ មនុស្សមិនអាចយល់អំពីព្រះគុណរបស់



Jonah - Gods Most Reluctant Prophet - 1.4.indd 38 9/6/26 9:03 in the morning

ព្រះសម្រាប់មនុស្សមានបាបបានទេ។ មនុស្សមិនអាចយល់អំពីមូលហេតុដែលព្រះអង្គប្រទានព្រះគុណ តែព្រះគុណព្រះអង្គបានឆ្លុះបញ្ចាំងឲ្យគេដឹងថា ព្រះអង្គជានរណា។

នៅក្នុងការឆ្លើយតប ចំពោះប្រតិកម្មរបស់លោក យ៉ូណាស ព្រះអម្ចាស់មិនបានសួរថា តើគាត់ខឹង ឬអត់ទេ ប៉ុន្តែព្រះអង្គសួរថា ការដែលគាត់ខឹងដូច្នេះ តើសមហេតុផលដែរឬទេ? លោក យ៉ូណាស គឺជាតំណាងឲ្យប្រជាជាតិមួយ ដែលព្រះអម្ចាស់បានជ្រើសរើស ទោះពួកគេបានវង្វេងចេញពីព្រះអង្គក៏ដោយ ហើយព្រះអង្គក៏បានជួយសង្គ្រោះពួកគេ ទោះពួកគេមិនស្តាប់បង្គាប់ព្រះអង្គក៏ដោយ។ ដូចនេះ ចំណុចស្នូលនៃបញ្ហារបស់គាត់ គឺស្ថិតនៅត្រង់ថា តើគាត់មានហេតុផលអ្វី ដែលត្រូវឃាត់ឃាំងព្រះអង្គមិនឲ្យមានសេចក្តីអាណិតចំពោះអ្នកដទៃ? ចម្លើយនោះគឺ គាត់គ្មានហេតុផលត្រឹមត្រូវទេ។ យើងក៏គ្មានសិទ្ធិឃាត់ឃាំងព្រះ មិនឲ្យបង្ហាញសេចក្តីមេត្តាចំពោះនរណាម្នាក់ឡើយ ហើយក៏គ្មានសិទ្ធិកំណត់ថា ព្រះអង្គត្រូវតែសង្គ្រោះរាស្ត្រព្រះអង្គ និងលើកតម្កើងព្រះរាជបុត្រារបស់ព្រះអង្គ តាមរបៀបណាមួយដែរ។

បើយើងខឹងនឹងព្រះ ហើយរអ៊ូរទាំអំពីរបៀបដែលព្រះអង្គសម្រេចព្រះទ័យបំពេញគោលបំណងរបស់ព្រះអង្គ នោះគឺដោយសារយើងបានភ្លេចថា យើងមានភាពមិនស័ក្តិសមប៉ុណ្ណា ក្នុងការទទួលព្រះគុណព្រះអង្គ។ យើងទ្រាំទ្រយ៉ាងខ្លាំង ចំពោះការមិនស្តាប់បង្គាប់របស់ខ្លួនឯង



Jonah - Gods Most Reluctant Prophet - 1.4.indd 39 9/6/26 9:03 in the morning

បានជាយើងគិតថា យើងស័ក្តិសមនឹងឲ្យព្រះអង្គសព្វព្រះទ័យនឹងយើង ហើយប្រទានពរយើង។ នេះជាផ្នត់គំនិតដ៏គ្រោះថ្នាក់។ អ្វីៗគ្រប់យ៉ាង ដែលព្រះអង្គធ្វើ គឺសុទ្ធតែដោយសារព្រះគុណព្រះអង្គទេ។ ទាល់តែ យើងបានស្គាល់ព្រះគុណព្រះច្បាស់ ទើបយើងអាចអរសប្បាយ នៅ ក្នុងសេចក្តីមេត្តាដ៏បរិបូររបស់ព្រះ ដែលបានចាក់មកលើពួកបរិសុទ្ធ ដែលមិនស័ក្តិសមរបស់ព្រះអង្គយ៉ាងហូរហៀរ។

*ព្រះគម្ពីរសញ្ជឹងគិត៖ យ៉ូណាស ៤*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៩៤-៩៦ និង កាឡាទី ១*



Jonah - Gods Most Reluctant Prophet - 1.4.indd 40
9/6/26 9:03 in the morning

Jonah - Gods Most Reluctant Prophet - 1.4.indd 41 9/6/26 9:03 in the morning

# ការរៀបចំដ៏អាចកំបាំងរបស់ព្រះអង្គ

*«ព្រះដ៏ជាព្រះយេហូវ៉ា ទ្រង់ក៏បំរុងឲ្យមានដើមវល្លិដុះឡើងគ្របបាំងយ៉ូណាស ដើម្បីឲ្យបានជាម្លប់ពីលើក្បាលប្រយោជន៍ឲ្យលោកបានរួចពីសេចក្តីតប់ប្រមល់ទៅ ដូច្នេះយ៉ូណាសមានសេចក្តីអំណរជាខ្លាំង ដោយព្រោះដើមវល្លិនោះ។ ប៉ុន្តែ ដល់ព្រឹកឡើងថ្ងៃក្រោយ ព្រះទ្រង់បំរុងឲ្យមានដង្កូវ១មកស៊ីដើមវល្លិ ឲ្យស្វិតក្រៀមវិញ»(យ៉ូណាស ៤:៦-៧)។*

កាលលោក យ៉ូណាស ចាកចេញពីទីក្រុងនីនីវេ ទីក្រុងនេះក៏បានសង្គ្រោះរួចផុតពីគ្រោះមហន្តរាយ ប៉ុន្តែគាត់មិនមាត់មិនករដោយចិត្តមួម៉ៅ។ គាត់ទូលព្រះអង្គថា ទូលបង្គំដឹងថា ព្រះអង្គបានអត់ទោសឲ្យពួកគេហើយ ទោះពួកគេបានធ្វើការអាក្រក់យ៉ាងណាក៏ដោយ។ ឥឡូវនេះ ទូលបង្គំសុខចិត្តស្លាប់ ប្រសើរជាងឃើញខ្មាំងសត្រូវរបស់ទូលបង្គំបានទទួលការអត់ទោសបាប (យ៉ូណាស ៤:២-៣)។

លោក យ៉ូណាស ក៏បានធ្វើកន្លែងជ្រកតូចមួយសម្រាប់ខ្លួនឯង (ខ.៥) ប្រហែលជាយកថ្ម ឬឥដ្ឋធ្វើពីភក់មកតម្រៀបពីលើ

គ្នា ដោយសារកម្តៅថ្ងៃអាចធ្វើឲ្យគាត់ពិបាកអង្គុយនៅកណ្តាលវាល។ សូមយើងស្រមៃថា គាត់កំពុងអង្គុយនៅក្នុងខ្ទមតូចមួយ សូមឲ្យព្រះដកជីវិតគាត់ ហើយបន្ទាប់មក គាត់ក៏បានដឹងថា មានរុក្ខជាតិដ៏ស្រស់ស្អាតបានដុះនៅក្បែរគាត់។ ភ្លាមៗនោះ កម្តៅថ្ងៃក៏បានថមថយ ដោយសារម្លប់ដែលដើមវល្លិនោះបានផ្តល់ឲ្យគាត់ ធ្វើឲ្យគាត់មានចិត្តរីករាយយ៉ាងខ្លាំង។

ប៉ុន្តែ គាត់រីករាយមិនបានយូរទេ។ ព្រះដែលបានប្រទានរុក្ខជាតិឲ្យលោក យ៉ូណាស សប្បាយចិត្ត ក៏បានប្រទានសត្វដង្កូវឲ្យស៊ីបំផ្លាញដើមនោះផងដែរ។ ស្លឹករបស់វាបានក្រៀមស្វិតអស់យ៉ាងឆាប់រហ័សខុសពីធម្មតា គឺដោយសារដំណើរការធម្មតាមួយស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះ។

ព្រះអាទិករមានអំណាចគ្រប់គ្រងមកលើអ្វីៗទាំងអស់ ដែលព្រះអង្គបានបង្កើត។ នៅក្នុងការរៀបចំដ៏អាថ៌កំបាំង ព្រះអង្គកំពុងបន្តធ្វើការជាមួយអ្នកបម្រើព្រះអង្គ តាមគោលបំណងរបស់ព្រះអង្គ។ ឃ្លា “ទ្រង់ក៏បម្រុង” គឺជាឃ្លាដែលត្រូវបានប្រើប្រាស់ម្តងហើយម្តងទៀតក្នុងកណ្ឌគម្ពីរយ៉ូណាស។ ព្រះអង្គបានបម្រុងឲ្យមានត្រីធំមួយ ដើមវល្លិ ដង្កូវ និងខ្យល់ក្តៅពីខាងលិច គឺបានបង្ហាញអំពីសេចក្តីស្រឡាញ់ និងការយកព្រះទ័យទុកដាក់ ចំពោះអ្នកបម្រើរបស់ព្រះអង្គ (យ៉ូណាស ១:១៧, ៤:៨)។ ទោះជាតាមរយៈត្រីធំ ឬដង្កូវតូចមួយក៏ដោយ ក៏ព្រះអង្គនៅតែធ្វើការរបស់ព្រះអង្គ ដើម្បីនាំឲ្យអ្វីៗទាំងអស់បានទៅដល់

គោលដៅដែលព្រះអង្គបានកំណត់។

យើងបានឃើញគោលលទ្ធិនៃការរៀបចំរបស់ព្រះក្នុងសំណួរទី២៧ នៃសៀវភៅសំណួរចម្លើយរបស់លោក ហៃដែលប៊ឺក (Heidelberg) ដែលសួរថា «តើអ្នកយល់ឃើញយ៉ាងណា អំពីការរៀបចំរបស់ព្រះ?» ចម្លើយ៖ «ការរៀបចំរបស់ព្រះ គឺជាព្រះវត្តមានដ៏មានអំណាច និងស្ថិតស្ថេរ ដែលក្នុងព្រះវត្តមាននោះ ព្រះអង្គទ្រទ្រង់ និងដឹកនាំស្នាព្រះហស្តទាំងអស់។ ព្រះអង្គទ្រទ្រង់អ្វីៗទាំងអស់នៅស្ថានសួគ៌ និងនៅលើផែនដី ដើម្បីធានាថា ផ្នែកទាំងអស់នៃជីវិតមិនកើតឡើងដោយចៃដន្យ ទោះវាជាការលូតលាស់នៃរុក្ខជាតិ លក្ខណៈអាកាសធាតុ ដូចជាភ្លៀង និងភាពរាំងស្ងួត ពេលខ្វះខាត ឬពេលបរិបូរ ការផ្គត់ផ្គង់អាហារ និងទឹក ស្ថានភាពនៃសុខភាព ឬជំងឺ ភាពមានបាន ឬភាពក្រីក្រក្តី។ ផ្ទុយទៅវិញ អ្វីៗកើតឡើង នៅក្រោមការថែរក្សាដោយក្តីស្រឡាញ់ និងតាមគោលបំណងរបស់ព្រះអង្គ»។[៣]

ក្នុងដំណើរជីវិតរបស់អ្នកទាំងមូល ពេលណាអ្នកជួប «ដើមវល្លិ» ដែលធ្វើឲ្យអ្នកសុខស្រួល និងសប្បាយចិត្ត និង «សត្វដង្កូវ» ដែលធ្វើឲ្យអ្នកបាត់បង់ភាពសុខស្រួល ឬទំនាក់ទំនងក្នុងការរស់នៅ អ្នកអាចរកឃើញការកម្សាន្តចិត្ត ដោយដឹងថា អ្នកមិនស្ថិតនៅក្រោមអំណាចដ៏ងងឹតងងល់ ដែលធ្វើឲ្យអស់សង្ឃឹមនោះឡើយ។ ផ្ទុយទៅវិញ ព្រះវរបិតារបស់អ្នកគង់នៅស្ថានសួគ៌ ដែលបានឱបក្រសោបអ្នក ដោយ

---

៣ Heidelberg Catechism, សំណួរ២៧។



Jonah - Gods Most Reluctant Prophet - 1.4.indd 43 9/6/26 9:03 in the morning

សេចក្ដីស្រឡាញ់កំពុងបង្គាប់អ្វីៗទាំងអស់ ដើម្បីឲ្យព្រះអង្គអាចសម្រេចគោលបំណងខ្ពស់បំផុតក្នុងជីវិតអ្នក គឺដើម្បីធ្វើឲ្យអ្នកមានលក្ខណៈដូចព្រះរាជបុត្រាព្រះអង្គ ហើយនាំអ្នកទៅរស់នៅជាមួយព្រះអង្គ។ ដូចនេះ ចូរពិចារណាអំពីជីវិតរបស់អ្នកចុះ។ តើមានដើមវល្លិនៅកន្លែងណា? ហើយមានដង្កូវនៅកន្លែងណា? តើអ្នកនឹងព្យាយាមអរព្រះគុណព្រះអង្គសម្រាប់ដើមវល្លិក៏ដូចជាសត្វដង្កូវដែរឬទេ ដោយដឹងច្បាស់ថា ព្រះវរបិតាបានប្រទានកត្តាទាំងពីរនេះមកដើម្បីជាប្រយោជន៍ដល់អ្នកដ៏អស់កល្ប?

*ព្រះគម្ពីរសញ្ជឹងគិត៖ យ៉ាកុប ១:៩-១៨*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ៩៦-៩៩ និង*
*កាឡាទី ២*



Jonah - Gods Most Reluctant Prophet - 1.4.indd 44 9/6/26 9:03 in the morning

# រឿងដែលគួរខ្វល់

*«ឯងបានអាល័យចំពោះដើមវល្លិ ដែលឯងមិនបានដាំ ឬធ្វើឲ្យដុះឡើងទេ ជាដើមដែលដុះឡើងក្នុង១យប់ ហើយបានវិនាសទៅក្នុង១យប់ដូចគ្នានោះ ដូច្នេះតើមិនគួរឲ្យអញអាល័យចំពោះក្រុងនីនីវេ ជាទីក្រុងយ៉ាងធំនេះ ដែលមានមនុស្សជាង១សែន២ម៉ឺននាក់ ជាពួកអ្នកដែលមិនស្គាល់ស្តាំមិនស្គាល់ឆ្វេងសោះ ព្រមទាំងហ្វូងសត្វយ៉ាងច្រើនផងទេឬអី?» (យ៉ូណាស ៤:១០-១១)។*

ហោរា យ៉ូណាស បានចាត់ទុកខ្លួនឯងជាជនរងគ្រោះ។ គាត់យល់ឃើញថា គាត់មិនមានកំហុសទេ នៅពេលដែលគាត់ជឿថា ទីក្រុងនីនីវេគួរតែទទួលការជំនុំជម្រះ ហើយព្រះអង្គមានកំហុស នៅពេលដែលព្រះអង្គសង្គ្រោះទីក្រុងនេះ។ គាត់ក៏បានជឿផងដែរថា ព្រះអង្គមានកំហុស ពេលដែលព្រះអង្គធ្វើឲ្យដើមវល្លិក្រៀមស្វិត បណ្តាលឲ្យគាត់ត្រូវកម្តៅថ្ងៃ។

ព្រះអង្គក៏បានឆ្លើយតប ដោយមិនបានសន្ទនាជាមួយគាត់ផ្តែកទៅលើការបដិសេធន៍ដ៏សោកសៅរបស់គាត់នោះទេ តែផ្ទុយទៅវិញ ព្រះអង្គបានលើកជាសំណួរដ៏សំខាន់មួយថា "ការដែលឯង



Jonah - Gods Most Reluctant Prophet - 1.4.indd 45 9/6/26 9:03 in the morning

ខឹងពីដំណើរដើមវល្លិនោះ តើគួរឬ?»(យ៉ូណាស ៤:៩)។ ត្រង់ចំណុចនេះ ព្រះអង្គនាំអារម្មណ៍គាត់ ឲ្យគិតអំពីរឿងតូចឡើងទៅដល់រឿងធំ ដោយសួរគាត់ថា បើគាត់អាចខ្វល់អំពីរុក្ខជាតិដែលបានដុះឡើង ហើយក្រៀមស្វិតទៅវិញក្នុងរយៈពេលតែមួយថ្ងៃ ចុះទម្រាំតែព្រះអង្គជាព្រះដ៏រស់វិញ តើព្រះអង្គមានសិទ្ធិខ្វល់អំពីប្រជាជននៅទីក្រុងនីនីវេជាងអម្បាលម៉ាន? ព្រះអង្គកំពុងត្រាស់ហៅលោក យ៉ូណាស ឲ្យពិចារណាឡើងវិញ អំពីការអ្វីដែលគាត់គួរឲ្យតម្លៃបំផុត។

សំណួររបស់ព្រះទៅកាន់លោក យ៉ូណាស ក៏ជាសំណួរសម្រាប់យើងផងដែរ។ តើមានរឿងអ្វីក្នុងជីវិតយើង ដែលយើងខ្វល់ខ្លាំងជាងការមើលឃើញអ្នកមិនជឿព្រះប្រែក្លាយជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទដោយការប្តេជ្ញាចិត្ត? បើយើងពិនិត្យមើលចិត្តខ្លួនឯងឲ្យបានដិតដល់ យើងប្រហែលជាកត់សម្គាល់ឃើញថា ទាក់ទងនឹងការប្រើប្រាស់ពេលវេលា អំណោយទាន ប្រាក់កាស និងសេរីភាពរបស់យើង យើងច្រើនតែចាត់ទុករឿងតូចតាច ជារឿងធំដោយមិនដឹងខ្លួន។ ពេលអ្នកដទៃសង្កេតមើលយើង ពួកគេអាចគិតថា យើងខ្វល់អំពីភាពសុខស្រួលរបស់ខ្លួនឯង ខ្លាំងជាងគិតអំពីវិញ្ញាណបាត់បង់ជាច្រើន ដែលមិនបានឮដំណឹងល្អ។

តើលោក យ៉ូណាស បានឆ្លើយតប ចំពោះសំណួររបស់ព្រះអង្គដូចម្តេចខ្លះ? យើងមិនដឹងទេ។ កណ្ឌគម្ពីរយ៉ូណាសបានបញ្ចប់ដោយសំណួរមួយនេះឯង។ ប៉ុន្តែ សំណួរសំខាន់បំផុតមិនបាន



Jonah - Gods Most Reluctant Prophet - 1.4.indd 46 9/6/26 9:03 in the morning

សួរថា តើលោក យ៉ូណាស បានឆ្លើយតបដូចម្ដេចនោះទេ? កណ្ឌគម្ពីរនេះទាំងមូលបាននិយាយសង្កត់ធ្ងន់ អំពីសេចក្ដីអាណិតរបស់ព្រះអម្ចាស់។ សំណួរសំខាន់បំផុតនោះគឺ តើយើងដែលជាអ្នកអានកណ្ឌគម្ពីរនេះ មានការយល់ដឹងយ៉ាងណា អំពីព្រះគុណរបស់ព្រះអង្គ?

តើយើងនឹងយកគំរូតាមព្រះអង្គ ដោយខ្វល់ខ្វាយអំពីអ្នកដទៃ ចង់ឲ្យពួកគេប្រែចិត្តចេញពីអំពើបាប ហើយទុកចិត្តព្រះអង្គដែរឬទេ? តើចិត្តយើងនឹងបានដូចចិត្តលោកយ៉ូណាស ឬដូចព្រះទ័យព្រះអម្ចាស់? នេះជាពេលដែលយើងត្រូវឈប់ខ្វល់អំពីបញ្ហាក្នុងលោកីយ៍ខ្លាំងជាងការឈោងចាប់វិញ្ញាណបាត់បង់ក្នុងសហគមន៍របស់យើងថ្វាយព្រះគ្រីស្ទ។ យើងមានអំណរដែលបានស្គាល់សេចក្ដីមេត្តារបស់ព្រះគ្រីស្ទក្នុងជីវិតយើងតាមរយៈព្រះយេស៊ូវ។ ហើយការឆ្លើយតបស័ក្កិសមបំផុតចំពោះឯកសិទ្ធិដ៏ប្រសើរនេះ គឺជាការលះបង់ផ្ទាល់ខ្លួន ដើម្បីឲ្យអ្នកដទៃបានស្គាល់ព្រះអង្គផងដែរ។ ព្រះអង្គសួរយើងថា តើយើងខ្វល់អំពីអ្វីជាងគេ? តើខ្វល់អំពីផ្ទះ? ទ្រព្យសម្បត្តិ? ឬឧបករណ៍ទំនើបៗរបស់អ្នក? ឬយើងខ្វល់អំពីមនុស្សនៅតាមផ្លូវ ដែលមិនដែលបានស្គាល់ព្រះយេស៊ូវ?

*ព្រះគម្ពីរសញ្ជឹងគិត៖ ម៉ាថាយ ២៨:១៦-២០*
*គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ៖ ទំនុកតម្កើង ១០០-១០២ និង កាឡាទី ៣*

ផ្លូវពិត
plovpit.com
















សេចក្តីបង្រៀនដ៏គួរឲ្យទុកចិត្តបានអំពីព្រះយេស៊ូវ
មាននៅ www.plovpit.com ក្នុងទម្រង់ជាកំណត់
ហេតុបណ្តាញ វីដេអូ  សំឡេង និងសៀវភៅ

# ផ្លូវពិត plovpit.com




**គេហទំព័រដែលមានព្រះគ្រីស្ទ**
**ជាគោលដើម្បីលើកទឹកចិត្ត**
**អ្នកជឿទាំងអស់។**

- វីដេអូ
- សៀវភៅ
- សៀវភៅជាសំឡេង
- កំណត់ហេតុបណ្ដាញ

youtube.com/plovpit
facebook.com/plovpit
instagram.com/plovpit

មានលក់ហើយ
នៅបណ្ណាគាររបស់យើង!

Selling now at our bookstore!

**$3.50**

សូមស្កែន

